I-ទីស្ដីការគណៈរដ្ឋមន្ត្រី

រាជធានីភ្នំពេញ ; ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យ

អនុក្រឹត្យលេខ ១២ អនក្រ
ស្ដីពីការផ្ទេរសណ្ឋាគារ វិមានរាជរដ្ឋាភិបាល
(Hotel Gouvernement)

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

សំរេច

មាត្រា ១ : ផ្ទេរសណ្ឋាគារវិមានរាជរដ្ឋាភិបាល (Hotel Gouvernement) ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មកស្ថិតក្រោមការគ្រប់គ្រង របស់ទីស្ដីការគណៈរដ្ឋមន្ត្រីវិញ ។

មាត្រា ២ : ចំ ះបុគ្គលិករាជការ ដែលបំរើការងារនៅសណ្ឋាគារនេះកន្លងមក ទីស្ដីការគណៈរដ្ឋមន្ត្រីទទួលយកនូវចំនួនដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិប្រគល់ជូន ។

មាត្រា ៣ : រាល់ចលនទ្រព្យ-អចលនទ្រព្យ បំរើអោយសណ្ឋាគារនេះកន្លងមក ត្រូវប្រគល់ជូនទីស្ដីការគណៈរដ្ឋមន្ត្រី គ្រប់គ្រង និង ប្រើប្រាស់តទៅ ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអានុភាពតតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១៣ អនក្រ
ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : ត្រូវបានបង្កើត ក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានសមាសភាពដូចតទៅ :

១_ឯកឧត្តម **សុខ អាន**	រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី	ជាសហប្រធាន
២_ឯកឧត្តម **វ៉េង សេរីវុឌ្ឍ**	រដ្ឋមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រី	ជាសហប្រធាន
៣_ឯកឧត្តម **សាយ បូរី**	រដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា	អនុប្រធាន
៤_ឯកឧត្តម **ហោ ចន្ទប៊ុនឆាត**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២	អនុប្រធាន
៥_ឯកឧត្តម **អ៊ុក វិបុល**	ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១	សមាជិក

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៦ : អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១៣ អនក្រ
ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : ត្រូវបានបង្កើត ក្រុមប្រឹក្សាអ្នកច្បាប់ ដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **សុខ អាន**	រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី	ជាសហប្រធាន
២-ឯកឧត្តម **វ៉េង សេរីវុឌ្ឍ**	រដ្ឋមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រី	ជាសហប្រធាន
៣-ឯកឧត្តម **សាយ បូរី**	រដ្ឋលេខាធិការទំនាក់ទំនងជាមួយសភា	អនុប្រធាន
៤-ឯកឧត្តម **ហេង ចន្ទ្រម៉ុនឆាត**	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២	អនុប្រធាន
៥-ឯកឧត្តម **អ៊ុក ទិធុន**	ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១	សមាជិក

៧_ឯកឧត្តម គង់ គិរុន	ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២	សមាជិក
៨_លោក កៅ ម៉ិនហុង	ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៩_លោក ចន្ទ គានី	ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១០_លោក ហែម ក្រាញ់ភូនី	ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

មាត្រា ២ ៖ ក្រុមប្រឹក្សាអ្នកច្បាប់មានភារកិច្ចដូចតទៅ:

- សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកគំរោងកសាងច្បាប់ ឬ លិខិតបទដ្ឋានថ្មីៗ ដែលមានការចាំបាច់សំរាប់បំរើអោយសកម្មភាពរាជរដ្ឋាភិបាល ។
- សិក្សា និងតាមដាន អត្ថបទច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលត្រូវបានប្រកាសចេញអោយប្រើ ដែលលែងសមស្រប នឹងសភាពការណ៍ជាក់ស្តែងដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាលធ្វើវិសោធនកម្ម ។
- សិក្សា និង ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រីអំពីសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិ ដែលបណ្តាក្រសួងស្ថាប័ន ផ្ញើរមកសុំសេចក្តីអនុម័តពីគណៈរដ្ឋមន្ត្រី ។
- ចាត់ចែងធ្វើសេចក្តីព្រាងច្បាប់ ឬ លិខិតបទដ្ឋាននៅជូនស្ថាប័នដែលមានសមត្ថកិច្ចផ្តល់សច្ចាប័នជាចុងក្រោយអោយបានសមស្របតាមនីតិវិធី ។

មាត្រា ៣ ៖ ក្រុមប្រឹក្សាអ្នកច្បាប់ មានក្រុមជំនាញមួយជាជំនួយការដែលមានសមាសភាពដូចខាងក្រោម :

១_លោក ឡេង ម៉េងឡុង	ជាប្រធាន
២_លោក ឡូ មេង	ជាអនុប្រធាន
៣_លោក គួច វណ្ណលី	ជាអនុប្រធាន
៤_លោក ឌី សូភីន	សមាជិក
៥_លោក កៅ គិមសរ	សមាជិក
៦_លោក អ៊ុក សារី	សមាជិក
៧_លោក គង់ ហេង	សមាជិក

មាត្រា ៤ : សមាជិកទាំងអស់ ព្រមទាំងក្រុមជំនួយការរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមាននាមក្នុងមាត្រា ១ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១៤ អនក្រ
ស្តីពីការបែងចែកខ្ទង់ចំណាយឥណទានធុក

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

មាត្រា ៤ : សមាជិកទាំងអស់ ព្រមទាំងក្រុមជំនួយការរបស់ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តមអស់លោក ដែលមាននាមក្នុងមាត្រា ១ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

***

រាជធានីភ្នំពេញ ,ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១៤ អនក្រ
ស្តីពីការបែងចែកខ្ទង់ចំណាយឥតគ្រោងទុក

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាយអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ផ្តល់ឥណទានបន្ថែម ដោយយកចេញពីជំពូក ៩១ " ចំណាយឥតគ្រោងទុក " នៃថវិការដ្ឋជូនទៅស្ថាប័ន ក្រសួងទាំងឡាយ ដូចខាងក្រោមនេះ ។

រដ្ឋសភា

ជំពូក ១១ :.. ២០០លានរៀល

ទីស្តីការគណៈរដ្ឋមន្ត្រី ផ្នែកទី ១ _ទីស្តីការគណៈរដ្ឋមន្ត្រី

ជំពូក ៥១ :.. ៨.៥៥០លានរៀល

ក្រសួងមហាផ្ទៃ ផ្នែកទី ២ _រដ្ឋបាលទូទៅ

ជំពូក ១០ :.. ៥៧០ លានរៀល

ជំពូក ១២ :.. ៣៥០ លានរៀល

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជំពូក ១០ :.. ៧០ លានរៀល

ជំពូក ១២ :.. ២.៧៥០ លានរៀល

ជំពូក ៣២ :.. ១.២៥០ លានរៀល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ជំពូក ១១ :.. ៥០ លានរៀល

ជំពូក ៣០ :.. ៥០០ លានរៀល

ក្រសួងអប់រំយុវជន និង កីឡា ផ្នែកទី ១ _អប់រំ

ជំ[illegible] :.. ១១.០០០ លានរៀល

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ជំពូក ៣០ :.. ១.៦២០ លានរៀល

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ជំពូក ៣១ :.. ២.០៥០ លានរៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២១ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែវិច្ឆិកាឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ
- តាមសំណើរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **យី ឆន់** ជាទីប្រឹក្សាអមក្រសួងធម្មការ និង សាសនា។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និងសាសនា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **យី ឆន់** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**